Public Health
Seattle & King County

KING COUNTY Healthcare Coalition
Prepare. Respond. Recover.



# ផែនការសម្រាប់ទឹកជំនន់នៅជ្រលងទន្លេគ្រីន:

## គំនិតសម្រាប់ការត្រៀមផ្ទាល់ខ្លួននៅតាមផ្ទះ សុខភាព & អ្នកជំងឺទទួលការថែទាំនៅតាមផ្ទះ

**កងវិស្វកម្មនៃកងទ័ពជើងគោកសហរដ្ឋអាមេរិកបានផ្តល់ដំណឹងឱ្យប្រុងប្រយ័ត្នចំពោះតំបន់ទំនប់ទឹក Howard Hanson ដែលមានបញ្ហាគ្រឹះនៅតាម ទំបន់ ដែលអាចនឹងមានកម្រិតសមត្ថភាព ស្តុកទឹកបាននៅក្នុងឆ្នាំនេះ និងប៉ុន្មានឆ្នាំខាងមុខនេះ ហើយអាចកើនឡើងច្រើនឆ្នាំក្រោយៗ**

តំបន់មួយចំនួននៃទីក្រុង **Auburn, Kent, Renton និង Tukwila** កំពុងប្រឈមមុខនឹងសក្តានុពលភាពខ្ពស់នៃទឹកជំនន់ខ្លាំងនៅរដូវស្លឹកឈើជ្រុះខាងមុខនេះ។ តំបន់មួយចំនួនដែលមិនជាប់នឹង King County ក៏ប្រហែលជានឹងរងការប៉ះពាល់ផងដែរ។ ប្រសិនបើមានភ្លៀងធ្លាក់ខ្លាំង និងយូរក្នុងរដូវភ្លៀង (ប្រហែលជាខែតុលា ដល់ខែមីនា) លំនៅដ្ឋាន និងជំនួញជាច្រើន នៅតំបន់ជិតទន្លេ Green ដែលមិនធ្លាប់លិចទឹក នឹងត្រូវ លិចទឹកជម្រៅ 10 ហ្វីត។ ម្យ៉ាងវិញទៀត ទឹកដែលនៅក្នុងជ្រលងនឹងនៅតែនៅទីនោះដដែល រហូតទាល់តែទឹកត្រូវបានបូមចេញ – ដំណើរការបូមនេះត្រូវការពេលរហូតដល់ 8 សប្តាហ៍។

**អាស្រ័យដោយទីតាំងរបស់អ្នកនៅជ្រលងទន្លេ Green យើងសូមលើកទឹកចិត្តឱ្យអ្នកត្រៀមទប់ទល់នឹងគ្រោះថ្នាក់ទឹកជំនន់ ដែលអាចនឹងកើតមានឡើង ហើយដែលមិនងាយស្រក់ទៅវិញនេះ។**

ប្រជាជនរស់នៅជិតទីក្រុង Auburn, Kent, Renton ឬ Tukwila និងតំបន់ទាំងឡាយណាដែលនៅមិនជាប់នឹង King Country គួរត្រៀមលក្ខណៈសម្រាប់គ្រោះថ្នាក់ដូចខាងក្រោម:

- **ការលិចទឹកពីតិចទៅខ្លាំង**
- **ការដាច់អគ្គិសនី**
- **ការដាច់សេវាទឹក**
- **ការបិទផ្លូវ**

**ចាត់វិធានការដូចខាងក្រោមឥឡូវនេះ ដើម្បីត្រៀមទប់ស្កាត់នឹងគ្រោះថ្នាក់នេះ:**

**ប្រសិនបើលោកអ្នករស់នៅតំបន់ជ្រលងទន្លេ Green សូមទិញការធានារ៉ាប់រងគ្រោះថ្នាក់ទឹកជំនន់។**

គោលនយោបាយធានារ៉ាប់រងគ្រោះថ្នាក់ទឹកជំនន់ ត្រូវការពេល 30ថ្ងៃ ដើម្បីមានប្រសិទ្ធភាព ដូច្នេះសូមលោកអ្នកទាក់ទងទៅភ្នាក់ងារធានារ៉ាប់រង ឬទៅកម្មវិធីជាតិធានារ៉ាប់រងទឹកជំនន់: **www.floodsmart.gov,1-888-379-9531**។

ត្រូវប្រាកដថា គោលនយោបាយធានារ៉ាប់រងលោកអ្នកគ្របដណ្តប់លើការខូចខាតដោយលូទឹកផងដែរ។

### រៀបចំផែនការផ្លាស់ទីលំនៅ។

លោកអ្នកប្រហែលជាមិនអាចត្រឡប់ទៅលំនៅដ្ឋានវិញឡើយ ក្នុងរយៈពេលច្រើនសប្តាហ៍ ឬច្រើនខែ។ ឥឡូវនេះ សូមលោកអ្នកបង្កើតផែនការ ដើម្បីឱ្យដឹងថា ទីកន្លែងមួយណា ដែលលោកអ្នកនឹងទៅស្នាក់នៅ និងទទួលការថែទាំ។ ត្រូវប្រាកដថា អ្នកថែទាំដឹងអំពីផែនការលំអិតរបស់លោកអ្នក។ បើលោកអ្នក មានសត្វចិញ្ចឹម សូមយកពួកវាទៅជាមួយផង។ រៀបចំកន្លែងសុវត្ថិភាពសម្រាប់ឱ្យសត្វលោកអ្នកនៅ។

### រៀបចំផែនការទំនាក់ទំនង។

បើលោកអ្នកត្រូវជន្លាសចេញ សូមប្រាកដថា លោកអ្នក អាចទំនាក់ទំនងអ្នកថែទាំ និងអ្នកដទៃទៀត ដែលអ្នកយល់ថា អាចពឹងពាក់បាន ដើម្បីឱ្យពួកគេស្គាល់ពីកន្លែង ដែលលោកអ្នកជន្លាសទៅ និងវិធីទាក់ទងមកលោកអ្នក។



**តពីទំព័រទី 1**

## ការរៀបចំផែនការជន្លាស។

លោកអ្នកអាចទទួលការជូនដំណឹងត្រឹមតែ 8 ម៉ោងប៉ុណ្ណោះ ដើម្បីជន្លាសចេញ។ សូមលោក អ្នកធ្វើការជាមួយអ្នកជិតខាងអ្នក ជាមួយអ្នកជាទីស្រឡាញ់ និងអ្នកថែទាំ ដើម្បីប្រាកដថា លោកអ្នកបានត្រៀមលក្ខណៈដូចខាងក្រោម :

- **ចង់សង្គ្រោះបន្ទាន់ "Go-Kit/កញ្ចប់សង្គ្រោះបន្ទាន់ "** (សូមមើលតារាងសម្ភារក្នុង **កញ្ចប់សង្គ្រោះបន្ទាន់→**)
- **សម្ភារសំខាន់ៗ** ត្រូវដាក់នៅកន្លែងងាយស្រួលយក មានសុវត្ថិភាព ដើម្បីអាចយកសម្ភារទាំងនោះមកប្រើយ៉ាងងាយស្រួល និងឆាប់រហ័ស។ សម្ភាររួមមាន :
  - ទូរស័ព្ទដៃ និងប្រដាប់បញ្ចូលភ្លើង
  - ធ្មេញដាក់
  - ឧបករណ៍ជំនួយការស្តាប់ & ថ្មបន្ថែម
  - រទេះកង់ ទំពក់ ឈើច្រត់ ឬឧបករណ៍ជំនួយការដើរផ្សេងៗទៀត
  - ម៉ាស៊ីនជំនួយការដកដង្ហើម
  - វ៉ែនតា និងកែវពាក់ក្នុងភ្នែកជាមួយទឹកលាងសំអាត
  - អាគុយ ឬឧបករណ៍សម្រាប់បញ្ចេះម៉ាស៊ីន AM ឬវិទ្យុទាក់ទង NOAA សម្រាប់ការប្រកាសអាសន្នអំពីអាកាសធាតុផ្សេងៗ។
- **ប្រសិនបើលោកអ្នកត្រូវការធ្វើការជន្លាស លោកអ្នកត្រូវមានមធ្យោបាយធ្វើដំណើរ ដែលអាចទុកចិត្តបាន។** ពិភាក្សាជាមួយមនុស្សជាទីស្រឡាញ់ របស់លោកអ្នក និងអ្នកថែទាំឥឡូវនេះ ដើម្បីរៀបចំផែនការផ្លាស់ទីលំនៅពីផ្ទះទៅកន្លែងសុវត្ថិភាព។ បើត្រូវការសេវាអ្នកជំនាញដឹកជញ្ជូនដើម្បីជន្លាស សូមជូន ដំណឹងដល់ភ្នាក់ងារ ថែទាំសុខភាពនៅ - Seattle & King County ជាមុន។
- **ផ្លូវជន្លាសចេញ។** ធ្វើការជាមួយអ្នកផ្តល់សេវាដឹកជញ្ជូន ដើម្បីរៀបចំផែនទីជន្លាសចេញ ដោយមិនពឹងផ្អែកលើផ្លូវរដ្ឋលេខ 167 ឬផ្លូវផ្សេងទៀត នៅតាមបណ្តោយជ្រលងទន្លេគ្រីន។ សូមចង់ចាំថា ផ្លូវដែលលោកអ្នកធ្វើដំណើររាល់ថ្ងៃ ប្រហែលជាត្រូវបិទដោយសារទឹកជំនន់។ ដូច្នេះ សូមធ្វើតាមការណែនាំ ដើម្បីជៀសវាងការជាប់គាំង និងស្ថានភាពគ្រោះថ្នាក់ !

### ប្រមូល "កញ្ចប់សង្គ្រោះបន្ទាន់" ដែលងាយស្រួលយកប្រើ និងដឹក ជញ្ជូន ដោយមានសម្ភារដូចខាងក្រោម :

- ថ្នាំពេទ្យ
- បញ្ជីឈ្មោះ និងលេខទូរស័ព្ទមនុស្សសំខាន់ៗ ដូចជាអ្នកថែទាំ មិត្តភក្តិ និងសមាជិកគ្រួសារ អ្នកផ្តល់សេវាកម្មធានារ៉ាប់រង និងម្ចាស់ផ្ទះ/អ្នកផ្តល់សេវាធានារ៉ាប់រងផ្ទះ។
- ព័ត៌មានសុខភាព ដូចជាឯកសារវេជ្ជបញ្ជា បញ្ជីឈ្មោះ បញ្ហាសុខភាព និងឈ្មោះ លេខទំនាក់ទំនងគ្រូពេទ្យ និងអ្នកថែទាំ។
- សំលៀកបំពាក់សំរាប់ប្តូរ
- អាហារ និងភេសជ្ជៈសម្រាប់ពេល 3ថ្ងៃ
- ថ្មពិលបន្ថែម សម្រាប់ឧបករណ៍អុកស៊ីសែន ឧបករណ៍ជំនួយការដកដង្ហើម ឧបករណ៍ជំនួយម្លេង ឧបករណ៍សរសៃប្រសាទ ទូរស័ព្ទ ឬឧបករណ៍សំខាន់ដទៃទៀត។ ចំណាំ : ដាវថ្មពិលតាមផ្លូវទឹកសម្រាប់បរិក្ខាវេជ្ជសាស្ត្រ ដែលដំណើរការដោយអគ្គិសនី សម្រាប់ប្រើប្រាស់ច្រើនម៉ោង។

**សម្រាប់ព័ត៌មានបន្ថែមសូម ទាក់ទងការិយាល័យគ្រប់គ្រងផ្នែកសង្គ្រោះបន្ទាន់ដែលស្ថិតនៅក្នុងទីក្រុងរបស់លោកអ្នក :**

| | |
|---|---|
| **ទីក្រុង** Auburn: | 253-876-1925 |
| **ទីក្រុង** Kent: | 253-856-4440 |
| **ទីក្រុង** Renton: | 425-430-6400 |
| **ទីក្រុង** Tukwila: | 206-433-1800 |
| **តំបន់មិនជាប់នឹង** King County: | 206-296-3830 |